**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍គោកធ្លក

## រយៈពេល ៥ ឆ្នាំ (២០១៧-២០២១)

ឈ្មោះសហគមន៍នេសាទ : គោកធ្លក

ភូមិ : ទួលទ្រា ព្រែកតាផ ព្រែកជា និងបាក់ដៃ

ឃុំ : គោកធ្លក

ស្រុក : អង្គរបុរី

ខេត្ត : តាកែវ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍គោកធ្លក

# រយៈពេល ៥ ឆ្នាំ (២០១៧-២០២១)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : គោកធ្លក |
| ភូមិ | : ទួលទ្រា ព្រៃកតាផ ព្រៃកដា និងបាក់ដៃ |
| ឃុំ | : គោកធ្លក |
| ស្រុក | : អង្គរបូរី |
| ខេត្ត | : តាកែវ |

# មាតិកា
# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១-ស្ថានភាពទូទៅ**

**២-អំពីប្រជាសាស្ត្រ**

ក- ប្រជាពលរដ្ឋ

ខ-មុខរបរ

**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍**

ក-ទីតាំង

ខ-ដែននេសាទ

គ-តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស

ឃ-ធនធានជលផល

**៤-ការធ្វើនេសាទ**

ក-អ្នកនេសាទ

ខ-ឧបករណ៍នេសាទ

គ-ការប៉ាន់ប្រមាណផលចាប់ប្រចាំឆ្នាំ

**៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ**

ក-ទស្សនៈវិស័យ

ខ-គោលបំណង

គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

គ២-ផែនការកែលម្អដែននេសាទ

គ៣-ផែនការរៀបចំកន្លែងអភិរក្ស

គ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ

គ៦-ផែនការផ្សព្វផ្សាយច្បាប់ជលផល

គ៧-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ

ឃ.ផែនការយុទ្ធសាស្ត្រ

-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៥ឆ្នាំ

-តារាងកម្មវិធីការងារ

-តារាងឧបសម្ព័ន្ធ

# ផែនការគ្រប់គ្រង
# តំបន់នេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទគោកធ្លក ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតលើកទី២ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ។

សហគមន៍នេសាទគោកធ្លកមានទីតាំងស្ថិតនៅភូមិទួលទ្រា ព្រៃកគាជ ព្រៃកដា និងបាក់ដៃ ឃុំគោកធ្លក ស្រុកអង្គរបូរី ខេត្តតាកែវ ដែលមានសមាជិកសរុបចំនួន ២៩៧នាក់ ប្រុស២១៤នាក់ ស្រី៨៣នាក់ និងមានគណៈកម្មការចំនួន ១១នាក់ ស្រី០២ និងមានគ្រួសារសរុប២៩៧ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួនរួមមាន៖

- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទថ្មី
- ផ្សព្វផ្សាយច្បាប់ស្តីពីជលផល
- ទប់ស្កាត់បទល្មើសនេសាទ
- ការពារព្រៃលិចទឹក
- យាមល្បាតជាប្រចាំ
- ការពារកន្លែងអភិរក្សត្រីមេពូជ
- ទំលាក់គល់ឈើ និងតាងជាជម្រកត្រី
- ធ្វើជម្រកត្រីនៅកន្លែងអភិរក្ស
- ចូលរួមសិក្ខាសាលា និងប្រជុំជាមួយខណ្ឌនិងអភិបាលខេត្ត ស្រុក
- ប្រជុំគណៈកម្មការក្នុងមួយខែពីរដង
- ប្រជុំជាមួយសាលាឃុំផ្សព្វផ្សាយពីប្រាក់ចំណូល
- ប្រជុំផ្សព្វផ្សាយបទល្មើស
- ចូលរួមជាថវិកាសាងសង់ស្ពាន ៧កន្លែង (ថ្មី៤ ជួសជុល៣កន្លែង)
- ចាក់ដីសាងសង់សាលារៀនព្រៃកគាជ (ជារមៀល)
- បរិចាកថវិកាដល់ឃុំជួសជុលសូឡា (១០០ដុល្លា)
- បរិចាកថវិកាដល់សាលារៀនអនុវិទ្យាល័យភ្នំដា (៥០ម៉ឺនរៀល)

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក-ប្រជាពលរដ្ឋ៖

- គ្រួសារសរុបក្នុងឃុំចំនួន ៧៣៩គ្រួសារ ចំនួនប្រជាពលរដ្ឋសរុបក្នុងតំបន់មាន៣១២៣នាក់ ប្រុសនាក់ ស្រី១៥២១នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន ៣០៥៧នាក់ ចាម៤០នាក់ និងវៀតណាមចំនួន ២៦នាក់ ។
- ចំនួនសមាជិកក្នុងសហគមន៍នេសាទ២៩៧នាក់

- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៧៨នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន២២នាក់ ប្រុស១០ ស្រី១២នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន៨៥នាក់ ប្រុស៧៦នាក់ ស្រី៥៥នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន២៦នាក់ ប្រុស១០នាក់ ស្រី១៦នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍អ្នកកាន់សាសនាព្រះពុទ្ធ៩៩%
- ប្រជាពលរដ្ឋក្នុងសហគមន៍អ្នកកាន់សាសនាយេស៊ូ៩៩%
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់ អ្នកមិនចេះអក្សរចំនួន៥១២នាក់ប្រុស២៨៥នាក់ ស្រី២២៧នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន១៥៨៩នាក់ ប្រុស៨៨១៥នាក់ ស្រី៨០១នាក់និងកំរិតមធ្យមសិក្សាចំនួន៩៨៥នាក់ ប្រុស៤៨១នាក់ ស្រី៤៧៩នាក់ ឧត្តមសិក្សាចំនួន៣៧នាក់ ប្រុស២១នាក់ ស្រី១៦នាក់ ។

ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ រួមមាន៖

- ធ្វើនេសាទចំនួន ៥០%
- ធ្វើស្រែចំនួន ៩០%
- ជាងផ្ទះចំនួន១%
- លក់ដូរចំនួន៥%
- កម្មករក្នុងនិងក្រៅស្រុកចំនួន ៥%
- ចិញ្ចឹមត្រីចំនួន ១%
- មន្ត្រីរាជការ ១%
-

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍គោកធ្លក ជាកន្លែងដែននេសាទទឹកសាបទើបបង្កើតថ្មី។

កន្លែងនេសាទសហគមន៍គោកធ្លក មានទំហំ៦៥៨២ហិកតា និងមានកំណត់និយាមកាដូចមានចែង នៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់៖

- ខាងជើងទល់នឹង : ឃុំព្រែកផ្ទោល ស្រុកអង្គរបុរី
- ខាងត្បូងទល់នឹង : ឃុំបុរីជលសារ ស្រុកបុរីជលសា និងប្រទេសវៀតណាម
- ខាងកើតទល់នឹង : ខេត្តកណ្តាល
- ខាងលិចទល់នឹង : ឃុំព្រែកផ្ទោល ស្រុកអង្គរបុរី

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍គោកធ្លក មានព្រែកចំនួន០៥ ប្រឡាយចំនួន០៣ កន្លែងអភិរក្សចំនួន០១ ។

| | |
|---|---|
| ១-ប្រឡាយលេខ០១២ | នេសាទ វិច្ឆិកា ដល់មិថុនា |
| ២- ព្រែកផ្ដោល | នេសាទ វិច្ឆិកា ដល់មិថុនា |
| ៣-ព្រែកក្រសាំង | នេសាទ វិច្ឆិកា ដល់មករា |
| ៤-ប្រឡាយលេខ០៩ | នេសាទ វិច្ឆិកា ដល់មិថុនា |
| ៥- ព្រែកឈូក | នេសាទ វិច្ឆិកា ដល់មិថុនា |
| ៦-ប្រឡាយលេខ០៥ | នេសាទ វិច្ឆិកា ដល់មិថុនា |
| ៧- ព្រែកបិនធាង | នេសាទ វិច្ឆិកា ដល់មិថុនា |
| ៨- ព្រែកបាក់ដៃ | នេសាទ វិច្ឆិកា ដល់មិថុនា |
| ៩- ប្រឡាយលេខ០៣ | នេសាទ វិច្ឆិកា ដល់មិនា |
| ១០- ស្ទឹងអង្គរបុរី | នេសាទពេញមួយឆ្នាំ |

១១- ព្រែអភិរក្សឈ្មោះ ទួលឡាំងកាក ទំហំ៣០ហិកតា

១២- ដីទំនាបលិចទឹកមាន ទំហំ៥៨៥៥ហិកតា

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- ចំណុចខាងជើងជាប់លានថ្ម ទំហំ១០ហិកតា
- ព្រៃឈ្មោះទួលឡាំងកាក ទំហំ៣០ហិកតា
- ព្រៃឈ្មោះកាំភ្លើងធំ ទំហំ៧ហិកតា
- ព្រៃឈ្មោះក្របីកូន ទំហំ៨ហិកតា

**ឃ-ធនធានជលផល**

**- ប្រភេទត្រីៈ**

ត្រីរ៉ស់ ត្រីព្រួល ត្រីប្រា ត្រីឆ្ដោ ត្រីឆ្លាំង ត្រីកែស ត្រីឆ្ដោក ត្រីក្អែក ត្រីទ្រនេន ត្រីត្រសក់ ត្រីគល់រាំង ត្រីខ្លា ត្រីកញ្ចុះ ត្រីលិញ ត្រីក្រាញ់ ត្រីចង្វារ ត្រីផ្ទោង ត្រីឆ្លូញ ត្រីពោធិ៍ ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីកន្ទ្រប់ ខ្លាំងហាយ ត្រីខ្មាន់ ត្រីកន្ធរ ត្រីក្រឡង់ ត្រីសណ្ដាយ ត្រីអណ្ដែង ត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្ទឹង ត្រីកញ្ជូនជ័យ ត្រីក្របី ត្រីគ្រុំ ត្រីឈ្កៀត ត្រីកញ្ជ្រូក ត្រីបណ្ដូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីក្រឹម ត្រីក្រឹមទន្សាយ ត្រីស្រកាក្ដាម ត្រីលលកសរ ត្រីឆ្ពិន ត្រីជញ្ជក់ ត្រីបណ្ដូលចេក ត្រីព្រលូង ត្រីកំពត ត្រីក្រពាត់ ត្រីក្រុស ត្រីកញ្ជាញ់ច្រាស កន្ត្រងប្រេង អណ្ដែងប៉ុយ ត្រីទឹកកៃ។ល។

**- ប្រភេទវារីសត្វៈ**

អណ្ដើក ពស់ ខ្យងគួចស្រួច ខ្យងគួចទាល ខ្យងចៃ (ខ្យងពណ៌លឿង) ក្ដាម អន្ទង់ កង្កែប កន្ធាយ កេ ឈ្លើង គ្រុំ លៀស អន្ទង់ ក្រពើ។ល។

**- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិៈ**

ដើមថ្លើមអណ្ដើក អូយយ៉ាស់(បន្លាយយួន) រាំង ប្របួយមេ ប្របួយឈ្មោល ស្បាត ភ្នំភ្លែង អញ្ចាញ កន្ទ្រង

ស្មែងក្របី កន្ធៀវ ធ្មេញត្រីញី ទៀនព្រៃ ត្រស់ ថ្វាង ត្នួ ខ្ទាយមាន់ វល្លិ៍ប្រេង វល្លិ៍ទឹកដោះ វល្លិ៍ត្រដិត វល្លិ៍ ដោះគន់ វល្លិ៍ត្រី វល្លិ៍ត្អើក ល្ពាក់ទឹក ស្លាបទា កន្ទាំងហៃ រញា ស្មោ ស្លត់ បន្លាឃ្លេ ផ្ទោល ថ្វាន់ ស្លូលទឹក ច្រកែង ប្រផេញ ផ្តៅ ក្អែកព្រាប បាក់ដង ត្រដក់ កន្ទុយអន្ទង់ ពោះក្អម វល្លិ៍អណ្តាតត្រកួត ក្រចាប់ សារាយសាប កំប្លោក ចកតូច ចកធំ កំពីងពួយស កំពីងពួយក្រហម ត្រកួន ព្រលិតអាចមន៍មាន់ ព្រលិតដូង រំចង់ ស្ពន់អំបោះ ត្រាវអណ្តែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប ចំប្លង កក់ជ្រុង កក់ក្តាម ឈូក ចន្ទល់ភ្នំ(វល្លិ៍ថ្គាល់ត្រី) កញ្ឆែត ស្មៅថ្មក់ទឹក ស្តន់ដំរី។ល។

## ៤-ការធ្វើនេសាទ

### ក-អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៨៦នាក់ ប្រុស៦០នាក់ ស្រី២៦នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៥៨៣នាក់ ប្រុស៥០០នាក់ ស្រី៨៣នាក់ ។
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន១៣៥នាក់ ប្រុស១០០នាក់ ស្រី៣៥នាក់ ។

### ខ.ឧបករណ៍នេសាទ

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|---|
| មង | ម៉ែត្រ | ៣២ | ២០០ម៉ែត្រ/គ្រួសារ | ៦៤០០ម៉ែត្រ ក្រលាពី ៤-៥ ស.ម | សីហា ដល់កុម្ភៈ |
| លបបង្កង | គ្រឿង | ៩ | ១០០គ្រឿង/គ្រួសារ | ១៨០គ្រឿង | សីហា ដល់មករា |
| សន្ទូចរនង | ផ្លែ | ១០ | ៥០០០ផ្លែ/គ្រួសារ | ៥០០ផ្លែលេខ ៤ | សីហា ដល់កុម្ភៈ |
| សំណាញ់ | វង់ | ២ | ១វង់/គ្រួសារ ១វង់=៥ម | ២វង់ ក្រឡាពី៣-៤ | វិច្ឆិកា ដល់មីនា |
| លបក្តាម | គ្រឿង | ៨ | ១០០គ្រឿង/គ្រួសារ | ៨០គ្រឿង | សីហា ដល់កុម្ភៈ |
| អួន | វង់ | ៣ | ១២ម៉ែត្រ/គ្រួសារ | ៣៦មក្រឡាពី៣-៤ស.ម | មករា ដល់កុម្ភៈ |
| សន្ទូចបង្កៃ | ផ្លែ | ៥ | ១០០ផ្លែ/គ្រួសារ | ២៥០ផ្លែ (ផ្លែលេខ ៥) | ធ្នូ ដល់មករា |
| លបកំពិស | គ្រឿង | ៤ | ១០០គ្រឿង/គ្រួសារ | ៤០គ្រឿង | សីហា ដល់ខែមករា |
| អង្រុត | គ្រឿង | ៣ | ១គ្រឿង/គ្រួសារ | ៣គ្រឿង | មករា ដល់កុម្ភៈ |
| លាន់អន្ទង់ | គ្រឿង | ៤ | ៥០គ្រឿង/គ្រួសារ | ៦០គ្រឿង | សីហា ដល់កុម្ភៈ |
| លបត្រីឆ្លាញ | គ្រឿង | ២ | ៩គ្រឿង/គ្រួសារ | ១៨គ្រឿង | សីហា ដល់កញ្ញា |
| លបត្រី | គ្រឿង | ៣ | ៥០គ្រឿង/គ្រួសារ | ១៥គ្រឿង | សីហា ដល់មករា |

| | | | | | |
|---|---|---|---|---|---|
| ថ្នង | វង់ | ១ | ១វង់/គ្រួសារ | ១វង់ | សីហា ដល់មករា |
| យ៉ាកនិងរបាំងព្រួល (១២កន្លែង) | គ្រឿង | | ១២គ្រឿង | ៣មx៥០ម | វិច្ឆិកាដល់មិថុនា |
| ដាយ(ព្រែកក្រសាំង និងខាងលើប៉ុស្តិ៍គយ) | វង់ | | ១វង់ | ៣០មx៧០ម | វិច្ឆិកាដល់មករា |

១-ប្រឡាយលេខ០១២របាំងព្រួលប្រវែង១៥មយ៉ាកទំហំ(៣មX៥០ម)នេសាទថ្ងៃទី០១/១១ដល់ថ្ងៃទី១៥ ខែ៦

២- ព្រែកថ្នោលរបាំងព្រួលប្រវែង៣០ម យ៉ាកទំហំ(៤មX៦០ម)នេសាទថ្ងៃទី០១/១១ដល់ ថ្ងៃទី១៥ ខែ០៦

៣- ចំណុចអ្នកតាក្រហមក ដាយត្រី ៣០មx៧០ម នេសាទថ្ងៃទី០១/១១ដល់ថ្ងៃទី៣០ខែ១

៤-ព្រែកក្រសាំង ដាយត្រីទំហំ(៣០មX៧០ម)នេសាទថ្ងៃទី០១/១១ ដល់ ថ្ងៃទី៣០ ខែ០១

៥-ប្រឡាយលេខ០៩ របាំងព្រួលប្រវែង៦ម យ៉ាកទំហំ(៤មX៦០ម)នេសាទថ្ងៃទី០១ ខែ១១ ដល់ថ្ងៃទី១៥ខែ០៦

៦- ព្រែកឈូករបាំងព្រួលប្រវែង៦ម យ៉ាកទំហំ (៣ម X ៥០ម) នេសាទថ្ងៃទី០១ ខែ១១ ដល់ថ្ងៃទី១៥ ខែ០៦

៧-ប្រឡាយលេខ០៥ របាំងព្រួលប្រវែង៦ម យ៉ាកទំហំ(៣មX៥០ម)នេសាទថ្ងៃទី០១ ខែ១១ដល់ថ្ងៃទី១៥ខែ០៦

៨- ព្រែកប៊ិនធាងរបាំងព្រួលប្រវែង៦ម យ៉ាកទំហំ (៣ម X៥០ម) នេសាទថ្ងៃទី០១ ខែ១១ ថ្ងៃទី១៥ ខែ០៦

៩- ចំណុចខាងលើប៉ុស្តិ៍គយ ១០០ម ដាយត្រីទំហំ(៣០មX៧០ម)នេសាទថ្ងៃទី០១ ខែ១១ ដល់ថ្ងៃ ទី៣០ ខែ០១

១០- ព្រែកបាក់ដៃ របាំងព្រួលប្រវែង៦ម យ៉ាកទំហំ(៣មX៥០ម) នេសាទថ្ងៃទី០១ ខែ១១ ដល់ថ្ងៃទី១៥ ខែ០៦

១១- ពីចំណុចព្រែកបាក់ដៃតាមព្រំដែនរហូតដល់ប្រឡាយលេខ០៣ របាំងប្រវែង១.៥០០ម នេសាទថ្ងៃទី១៥ ខែ៧ ដល់ថ្ងៃទី១៥ ខែ០៣

១២- ពីចំណុចព្រែកកកែតាមព្រំដែនរហូតដល់ប្រឡាយ១.០០០ របាំងប្រវែង១.៥០០ម នេសាទចាប់ពី ថ្ងៃទី១៥ ខែ៧ ដល់ថ្ងៃទី១៥ ខែ០៣

១៣-ទីតាំងដងស្ទឹងអង្គរបូរីចាប់ពីប្រឡាយលេខ០១២រហូតដល់ប្រឡាយលេខ០៩ និងចាប់ពីមណ្ឌលសុខភាពគោកធ្លក រហូតដល់ ព្រែកបាក់ដៃ ឧបករណ៍ម៉ាញ់ ទំហំ(៣០ម X ៥០ម) ចំនួន០៣វង់ រួមផ្សំដោយម៉ាស៊ីនកម្លាំង១០សេះ នេសាទថ្ងៃទី០១ ខែ១១ ដល់ថ្ងៃទី១៥ ខែ០៤ ។

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| កាណូត | ៥៨០គ្រឿង | ១០០-២៥០០គីឡូក្រាម | ៦,៥-២៤សេស |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួនគ្រួសារ | ចំនួនឧបករណ៍នេសាទ | ទំហំ/ប្រវែង |
|---|---|---|---|---|
| មង | ម៉ែត្រ | ១២០ | ២០០ម៉ែត្រ/គ្រួសារ | ២៤០០០ម៉ែត្រក្រលាពី ៤-៥ ស.ម |
| លបបង្គង | គ្រឿង | ១១០ | ២០គ្រឿង/គ្រួសារ | ២២០០គ្រឿង |
| សន្ទូចរនង | ផ្លែ | ៧៧ | ៥០ផ្លែ/គ្រួសារ | ៣៨៥០ផ្លែលេខ ៤ |
| សំណាញ់ | វង់ | ៣៤ | ១វង់/គ្រួសារ ១វង់=៥ម | ៣៤វង់ ក្រឡាពី៣-៤ |

| | | | | |
|---|---|---|---|---|
| លបក្តាម | គ្រឿង | ៩៩ | ១០គ្រឿង/គ្រួសារ | ៩៩០គ្រឿង |
| អួន | វង់ | ១០ | ១២ម៉ែត្រ/គ្រួសារ | ១២០ម៉ែត្រ ក្រឡាពី ៣-៤ ស.ម |
| សន្ទូចបង្កៃ | ផ្លែ | ១៨ | ៥០ផ្លែ/គ្រួសារ | ៩០០ផ្លែ (ផ្លែលេខ ៥) |
| លបកំពិស | គ្រឿង | ៣០ | ១០គ្រឿង/គ្រួសារ | ៣០០គ្រឿង |
| អង្រុត | គ្រឿង | ១២ | ១គ្រឿង/គ្រួសារ | ១២គ្រឿង |
| លាន់អន្ទង់ | គ្រឿង | ១៣ | ១៥គ្រឿង/គ្រួសារ | ១៩៥គ្រឿង |
| លបត្រីឆ្លូញ | គ្រឿង | ២១ | ៩គ្រឿង/គ្រួសារ | ១៨៩គ្រឿង |
| លបត្រី | គ្រឿង | ១១ | ៥គ្រឿង/គ្រួសារ | ៥៥គ្រឿង |
| ថ្នង | វង់ | ២៨ | ១វង់/គ្រួសារ | ២៨វង់ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| កាណូត | ៦៥០ | ១០០-២៥០០គីឡូក្រាម | ៦,៥-២៤សេស |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នក មិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន គ្រួសារ | ចំនួនឧបករណ៍ នេសាទ | ទំហំ/ប្រវែង |
|---|---|---|---|---|
| មង | ម៉ែត្រ | ៥១ | ២០០ម/គ្រួសារ | ៥១០០មក្រឡាពី ៤-៥ ស.ម |
| លបក្តាម | គ្រឿង | ៣០ | ៥០គ្រឿង/គ្រួសារ | ១៥០០ម ក្រឡាពី ៣-៤ ស.ម |
| សន្ទូចរនង | ផ្លែ | ១២ | ៥០ផ្លែ/គ្រួសារ | ៦០០ផ្លែលេខ ៤ |
| លបបង្កង | គ្រឿង | ១១ | ៥០គ្រឿង/គ្រួសារ | ៥៥០គ្រឿង |
| ថ្នង | វង់ | ១០ | ១វង់/គ្រួសារ | ១០វង់ |
| សំណាញ់ | វង់ | ៦ | ១វង់/គ្រួសារ | ៦វង់ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| កាណូត | ៨០គឿង | ១០០-១៥០០គីឡូក្រាម | ៦,៥-១៥សេស |

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីចម្រុះ | ១៥០គីឡូក្រាម | ២៧០គីឡូក្រាម | ៤២០គីឡូក្រាម |
| វារីសត្វ (ខ្យង ក្តាម) | | ១០០០គីឡូក្រាម | ១០០០គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក-ទស្សនៈវិស័យ

សហគមន៍នេសាទគោកធ្លកមានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ-គោលបំណង

-ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុបពីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិច ទឹកក្នុងរដូវតំឡើងនាទីព្រៃលិចទឹក ។

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

### គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ១-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

| រៀបចំកន្លែងអភិរក្ស | ទំហំ(ហ.ត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ចំណុចលានថ្ម | ១០ហិកតា | -ត្រីមេពូជ<br>-ការពារព្រៃលិចទឹក<br>-ធ្វើជម្រកត្រី | ១ដង/ឆ្នាំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានដឹងពីកន្លែងអភិរក្សនិងហាមឃាត់រាល់ការធ្វើនេសាទគ្រប់ប្រភេទ | ០១/០១/២០១៧ | ៣០/០៣/២០២១ | |
| | | | ដាក់ស្លាកសញ្ញា ៨ស្លា | ០១/០១/២០១៨ | ០១/០២/២០២១ | |
| | | | ដាំបង្គោលព្រំប្រទល់កន្លែងអភិរក្ស៩ដើម | ១៥/០៣/២០១៩ | ១៥/០៣/២០២១ | |
| | | | ធ្វើជម្រកសិប្បនិម្មិត (ដាក់ឬស្សីព័ទ្ធជុំវិញនិងដាក់កំប្លោកជាជម្រកត្រី) | ១៥/០២/២០១៧ | ១៥/០២/២០២១ | |

#### គ២-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ

ផែនការចុះទប់ស្កាត់បទល្មើសនេសាទត្រូវបានរៀបចំដូចខាងក្រោមៈ

| សកម្មភាព | លទ្ធផលរំពឹងទុក | ចំណាយ ដុល្លា | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នជំនាញដើម្បីសហការបានល្អតាមរយៈការប្រជុំរបស់គណៈកម្មការសហគមន៍ នេសាទ | ដង/ឆ្នាំ អាជ្ញាធរមូលដ្ឋាននិងជំនាញផល ផលចូលរួមរាល់សកម្មភាពអនុវត្ត | ២០០/ម្តង x១៥ដង =$៣០០០ | - អង្គការដៃគូ<br>- រដ្ឋបាលជលផល<br>- គណៈកម្មការ សហគមន៍នេសាទ<br>- អាជ្ញាធរមូលដ្ឋាន | ០១/០១/២០១៧ | ៣០/០៣/២០២១ |
| ប្រជុំពិភាក្សាគណៈកម្មការ សហគមន៍រៀបចំផែនការប្រចាំខែ និងត្រីមាស | ៤ដង/ឆ្នាំជាមួយគណៈកម្មការ ទទួលបាននូវបទពិសោធន៍និងចំណេះដឹងថ្មីៗលើ ការដោះស្រាយ បញ្ហានិងមានការកែលម្អកាន់តែ ប្រសើរឡើង | ១០០/ម្តង x២០ដង =$២០០០ | - គណៈកម្មការ សហគមន៍នេសាទ | ០១/០១/២០១៧ | ៣០/០៣/២០២១ |
| រៀបចំកំលាំងចុះបង្ក្រាបដល់ទីកន្លែងដោយសហការជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នជំនាញ | ២៣ដង/ខែ ឧបករណ៍នេសាទខុសច្បាប់ថយចុះបណ្តើៗ និងឈានទៅលុបបំបាត់ទាំងស្រុង | ២៤០០/ឆ្នាំ ២៤០០x៥ឆ្នាំ = $១២០០០ | - អង្គការដៃគូ<br>- រដ្ឋបាលជលផល<br>- គណៈកម្មការ សហគមន៍នេសាទ<br>- អាជ្ញាធរមូលដ្ឋាន | ០១/០១/២០១៧ | ៣០/០៣/២០២១ |

**គ៣-ផែនការប្រើប្រាស់ឧបករណ៍នេសាទ**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមណ៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ល.រ | ទីតាំងកន្លែងនេសាទ | ប្រភេទឧបករណ៍ ទំហំ/ប្រវែង | ថ្ងៃខែចាប់ផ្តើម | ថ្ងៃខែបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ប្រឡាយ១២ | យ៉ាក ៣មx ៥០ម របាំងព្រួលប្រវែង១៥ម | ថ្ងៃទី០១ខែវិច្ឆិកា | ថ្ងៃទី១៥ខែមីថុនា | គណៈកម្មកាសហគមន៍ |
| ២ | ព្រែកផ្តោល | យ៉ាក ៤មx ៦០ម របាំងព្រួលប្រវែង៣០ម | ថ្ងៃទី០១ខែវិច្ឆិកា | ថ្ងៃទី១៥ខែមីថុនា | គណៈកម្មកាសហគមន៍ |
| ៣ | ចំនុចអ្នកតាក្រហមក | ដាយត្រី៣០មx ៧០ម | ថ្ងៃទី០១ខែវិច្ឆិកា | ថ្ងៃទី៣០ខែមករា | គណៈកម្មកាសហគមន៍ |
| ៤ | ព្រែកក្រសាំង | ដាយត្រី៣០មx ៧០ម | ថ្ងៃទី០១ខែវិច្ឆិកា | ថ្ងៃទី៣០ខែមករា | គណៈកម្មកាស |

| | | | | | |
|---|---|---|---|---|---|
| | | | | | ហគមន៍ |
| ៥ | ប្រឡាយ០៩ | យ៉ាក ៤មX ៦០ម<br>របាំងព្រួលប្រវែង៦ម | ថ្ងៃទី០១ខែវិច្ឆិកា | ថ្ងៃទី១៥ខែមិថុនា | គណៈកម្មការស<br>ហគមន៍ |
| ៦ | ព្រែកឈូក | យ៉ាក ៣មX ៥០ម<br>របាំងព្រួលប្រវែង៦ម | ថ្ងៃទី១៥ខែមិថុនា | ថ្ងៃទី១៥ខែមិថុនា | គណៈកម្មការស<br>ហគមន៍ |
| ៧ | ប្រឡាយ០៥ | យ៉ាក ៣មX ៥០ម<br>របាំងព្រួលប្រវែង៦ម | ថ្ងៃទី០១ខែវិច្ឆិកា | ថ្ងៃទី១៥ខែមិថុនា | គណៈកម្មការស<br>ហគមន៍ |
| ៨ | ព្រែកប៊ិនផាង | យ៉ាក ៣មX ៥០ម<br>របាំងព្រួលប្រវែង៦ម | ថ្ងៃទី០១ខែវិច្ឆិកា | ថ្ងៃទី១៥ខែមិថុនា | គណៈកម្មការស<br>ហគមន៍ |
| ៩ | ខាងលើប៉ុស្តិ៍គយ១០០ម | ដាយត្រី៣០មX ៧០ម | ថ្ងៃទី០១ខែវិច្ឆិកា | ថ្ងៃទី៣០ខែមករា | គណៈកម្មការស<br>ហគមន៍ |
| ១០ | ព្រែកបាក់ដៃ | យ៉ាក ៣មX ៥០ម<br>របាំងព្រួលប្រវែង៦ម | ថ្ងៃទី០១ខែវិច្ឆិកា | ថ្ងៃទី១៥ខែមិថុនា | គណៈកម្មការស<br>ហគមន៍ |
| ១១ | ពីព្រែកបាក់ដៃតាមព្រំដែនរហូត<br>ដល់លើប្រឡាយលេខ០៣ | របាំងប្រវែង១៥០០ម | ថ្ងៃទី១៥ខែកក្កដា | ថ្ងៃទី១៥ខែមីនា | គណៈកម្មការស<br>ហគមន៍ |
| ១២ | ពីព្រែកកកែតាមព្រំដែនរហូត<br>ដល់លើប្រឡាយលេខ១០០០ | របាំងប្រវែង១៥០០ម | ថ្ងៃទី១៥ខែកក្កដា | ថ្ងៃទី១៥ខែមីនា | គណៈកម្មការស<br>ហគមន៍ |
| ១៣ | ដងស្ទឹងអង្គបុរីចាប់ពីប្រឡាយ<br>១២រហូតដល់ប្រឡាយលេខ០៩<br>និងចាប់ពីមណ្ឌលសុខភាពគោក<br>ធ្លករហូតដល់ព្រែកបាក់ដៃ | ម៉ាញ់៣០មX៥០មចំនួន៣<br>វង់ រួមផ្សំម៉ាស៊ីន១០សេះ | ថ្ងៃទី០១ខែវិច្ឆិកា | ថ្ងៃទី១៥ខែមេសា | គណៈកម្មការស<br>ហគមន៍ |

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| **បឹងនិងស្ទឹង** | **ខែសីហា ដល់ ខែកុម្ភៈ** | មង | ៦០,៤០០ម x ១,៥ម ក្រឡា៤-៥ សម | ៣០២គ្រួសារ<br>២០០ម/គ្រួសារ | សមាជិកសហគមន៍មិនអនុញ្ញាតឱ្យនេសាទមុខរបាំង ចម្ងាយ ២០០ម |
| | | សន្ទូចរនង | ១៩៨០០ផ្លែ<br>ផ្លែលេខ ៤ | ៩៩គ្រួសារ<br>២០០ផ្លែ/គ្រួសារ | សមាជិកសហគមន៍មិនអនុញ្ញាតឱ្យនេសាទមុខរបាំង ចម្ងាយ ២០០ម |
| | | លបក្តាម | ៦៨៥០លប | ១៣៧គ្រួសារ<br>៥០ផ្លែ/គ្រួសារ | សមាជិកសហគមន៍មិនអនុញ្ញាតឱ្យនេសាទមុខរបាំង ចម្ងាយ ២០០ម |
| | | លាន់អន្ទង់ | ២៥៥គ្រឿង | ១៧គ្រួសារ<br>១៥គ្រឿង/គ្រួសារ | សមាជិកសហគមន៍មិនអនុញ្ញាតឱ្យនេសាទមុខរបាំង ចម្ងាយ ២០០ម |
| | | លបត្រី | ៧០លប | ១៤គ្រួសារ<br>៥លប/គ្រួសារ | សមាជិកសហគមន៍មិនអនុញ្ញាតឱ្យនេសាទមុខរបាំង ចម្ងាយ២០០ម |
| | | លបកំពិស | ៣៤០គ្រឿង | ៣៤គ្រួសារ<br>១០គ្រឿង/គ្រួសារ | សមាជិកសហគមន៍មិនអនុញ្ញាតឱ្យនេសាទមុខរបាំង ចម្ងាយ២០០ម |
| | | | | | |
| | | ថ្នង | ៣៩គ្រឿង | ៣៩គ្រួសារ<br>១គ្រឿង/គ្រួសារ | សមាជិកសហគមន៍មិនអនុញ្ញាតឱ្យនេសាទមុខរបាំង ចម្ងាយ២០០ម |

| | | | | | |
|---|---|---|---|---|---|
| | | អួន | ១៣វង់ | ១៣គ្រួសារ<br>១វង់/គ្រួសារ | សមាជិកសហគមន៍មិនអនុញ្ញាតឱ្យនេសាទមុខរបាំងចម្ងាយ២០០ម |
| | | សន្ទូចបង្កៃ | ១១៥០ផ្លែ | ២៣គ្រឿង<br>៥០ផ្លែ/គ្រួសារ | សមាជិកសហគមន៍មិនអនុញ្ញាតឱ្យនេសាទមុខរបាំងចម្ងាយ២០០ម |
| | | អង្រុត | ១៥គ្រឿង | ១៥គ្រួសារ<br>១គ្រឿង/គ្រួសារ | សមាជិកសហគមន៍មិនអនុញ្ញាតឱ្យនេសាទមុខរបាំងចម្ងាយ២០០ម |

| សកម្មភាព | លទ្ធផលរំពឹងទុក | ចំណាយ ថវិកា | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ២ដង/ឆ្នាំ<br>ប្រជុំផ្សព្វផ្សាយអំពីផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍នេសាទគោកធ្លក | - សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍<br>- ឧបករណ៍នេសាទល្មើសច្បាប់ថយចុះជាបណ្តើរៗ<br>- ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានពេញមួយឆ្នាំ | ១០/ម្តង<br>២៥០X១០ ដង<br>=$២៥០០ | - អង្គការដៃគូ<br>- រដ្ឋបាលជលផល<br>- គណៈកម្មការសហគមន៍នេសាទ<br>- អាជ្ញាធរមូលដ្ឋាន | ០១/០១/២០១៧ | ៣០/០៣/២០២១ |
| បិទផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទ<br>២ដង/ឆ្នាំ | | ១០/ម្តង<br>១៥០X១០ ដង<br>=$១២៥០ | - គណៈកម្មការសហគមន៍នេសាទ | ០១/០១/២០១៧ | ៣០/០៣/២០២១ |
| ផ្សព្វផ្សាយតាមមេក្រូនូវផែនការប្រើប្រាស់ឧបករណ៍នេសាទ<br>២ដង/ឆ្នាំ | | ១០/ម្តង<br>១០០X១០ ដង<br>=$១០០០ | - គណៈកម្មការសហគមន៍នេសាទ | ០១/០១/២០១៧ | ៣០/០៣/២០២១ |

### គ៤-ផែនការផ្សព្វផ្សាយច្បាប់ស្តីពីជលផល

ផែនការផ្សព្វផ្សាយច្បាប់ជលផលត្រូវបានរៀបចំឡើងដូចខាងក្រោម :

| សកម្មភាព | លទ្ធផលរំពឹងទុក | ចំណាយ ថវិកា | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| -ផ្សព្វផ្សាយតាមការប្រជុំ | ២ដង/ឆ្នាំ<br>ប្រជាពលរដ្ឋបានយល់ច្បា | ១០/ម្តង | -អង្គការដៃគូ<br>-រដ្ឋបាល | ០១/០១/២០១៧ | ៣០/១២/២០២១ |

| | | | | | |
|---|---|---|---|---|---|
| -ផ្សព្វផ្សាយតាមមេក្រូ<br>-ផ្សព្វផ្សាយតាមរយៈចែកឯកសារ | ប់ជ.ផ ហើយឈប់ប្រព្រឹត្តការធ្វើនេសាទផ្ទុយនឹងច្បាប់ជលផល | ១៥០X១០ផង<br>=$១៥០០ | ជលផល<br>-គណៈកម្មការសហគមន៍នេសាទ<br>-អាជ្ញាធរមូលដ្ឋាន | | |

## គ៥-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម :

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំចាប់បញ្ចប់ | ចំណូលសរុបដុល្លា | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | -ផ្សព្វផ្សាយជ្រើសរើសសមាជិក និងបង់ប្រាក់ភាគទាន<br>-ប្រមូលភាគទាន ៥០០រៀល/ម្នាក់ | ០១/០១/២០១៧ | ២៥/០២/២០២១ | ៣៧ | ៥០០រៀល/១នាក់/១ឆ្នាំ រយៈពេល៥ឆ្នាំ |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំ ១០០០រៀល/ម្នាក់ | ០១/០១/២០១៧ | ២៥/០២/២០២១ | ៣៧១ | ១០០០រៀល/នាក់ បង់រាល់ឆ្នាំ រយៈពេល៥ឆ្នាំ |
| ធ្វើអាជីវកម្មនេសាទ | បោះរបាំងដាក់យ៉ក្នុងព្រែកចំនួន៥ | ០១/១១/២០១៧ | ០១/១១/២០២១ | ៣០០០ | រយៈពេល ៥ឆ្នាំ |
| ធ្វើអាជីវកម្មនេសាទ | ឧបករណ៍ចំនួន០៣វង់ | ០១/១១/២០១៧ | ០១/១១/២០២១ | ១០០០ | រយៈពេល ៥ឆ្នាំ |
| ធ្វើអាជីវកម្មនេសាទ | បោះរបាំងដាក់យ៉ក្នុងប្រឡាយចំនួន៣ | ០១/១១/២០១៧ | ០១/១១/២០២១ | ១៧០០ | រយៈពេល ៥ឆ្នាំ |
| ធ្វើអាជីវកម្មនេសាទ | បោះរបាំងតាមព្រំដែនចំនួន២ | ០១/១១/២០១៧ | ០១/១១/២០២១ | ៥០០ | រយៈពេល ៥ឆ្នាំ |
| | | | សរុប | $=៦៦០៨ | |

## ឃ.ផែនការយុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម :

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមាន: សមាជិកគណៈកម្មការសហកមន៍នេសាទចាស់ទុំដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែង

អភិរក្ស ព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម

- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បី ទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់ និងផែនការសកម្មភាពប្រចាំឆ្នាំ
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិការ និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់
- រៀបចំធ្វើស្នាក់ការសហគមន៍នេសាទចំនួនមួយខ្នង និងទិញទូកម៉ាស៊ីនចំនួន០២គ្រឿង សម្រាប់គ្រប់គ្រងដៃរក្សាការពារកន្លែងនេសាទសហគមន៍ ។

***

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល ៥ឆ្នាំ (២០១៧.ដល់២០២១)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មាន (ដុល្លា) | ប្រភពជំនួយ | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១-ការរៀបចំកន្លែងអភិរក្ស | ១ដង/ឆ្នាំ<br>ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានដឹងពីកន្លែងអភិរក្សនិងហាមឃាត់រាល់ការធ្វើនេសាទគ្រប់ប្រភេទ | សមាជិកសហគមន៍នេសាទនិងប្រជាពលរដ្ឋក្នុងនិងក្រៅសហគមន៍ចូលរួម ថែរក្សា ការពារធនធាន | ២៥០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-គណៈកម្មការសហគមន៍នេសាទ<br>-អាជ្ញាធរមូលដ្ឋាន | ១៥/០៣-០៥/២០១៧ | ១៥/០៣-០៥/២០១៧ | |
| | ដាក់ស្លាកសញ្ញា ៨ស្លា | សមាជិកសហគមន៍យល់ដឹងពីការហាមឃាត់ការធ្វើនេសាទក្នុងតំបន់អភិរក្ស | ១៦០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-គណៈកម្មការសហគមន៍នេសាទ<br>-អាជ្ញាធរមូលដ្ឋាន | ២០/០១/២០១៨ | ២០/០២/២០២១ | |
| | ដាំបង្គោលព្រំប្រទល់កន្លែងអភិរក្ស៩ដើម | សមាជិកសហគមន៍យល់ដឹងពីព្រំប្រទល់កន្លែងអភិរក្សជលផល | ៧៥០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-គណៈកម្មការសហគមន៍នេសាទ<br>-អាជ្ញាធរមូលដ្ឋាន | ២៥/០៣/២០១៩ | ២៥/០៣/២០២១ | |
| | ធ្វើជម្រកសិប្បនិម្មិត (ដាក់ឬស្សីព័ទ្ធជុំវិញនិងដាក់កំប្លោកជាជម្រកត្រី) | - មានជម្រកសម្រាកត្រីពងកូន<br>- ធនធានជលផលមានមូប់សម្រាប់ជ្រក<br>- ធនធានជលផលកើនឡើង | ១៧៥០០ | អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-គណៈកម្មការសហគមន៍នេសាទ<br>-អាជ្ញាធរមូលដ្ឋាន | ១៥/០២/២០១៧ | ១៥/០២/២០២១ | |
| ២-ការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ | ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នជំនាញដើម្បីសហការបានល្អតាមរយៈការប្រជុំ | ២ដង/ឆ្នាំ<br>អាជ្ញាធរមូលដ្ឋាននិងជំនាញជលផលចូលរួមរាល់សកម្មភាពអនុវត្ត | ៣០០០ | - អង្គការដៃគូ<br>- រដ្ឋបាលជលផល<br>- គណៈកម្មការសហគមន៍នេសាទ | ០១/០១-០៥-០៩/២០១៧ | ០១/០១-០៥-០៩/២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | របស់សហគមន៍ស្របទៅតាមគោលការណ៍ណែនាំនៃច្បាប់ | | - អាជ្ញាធរមូលដ្ឋាន | | | |
| | ប្រជុំពិភាក្សាគណៈកម្មការស.ន រៀបចំផែនការប្រចាំខែនិងត្រីមាស | ៤ដង/ឆ្នាំជាមួយ គណៈកម្មការទទួលបាននូវបទពិសោធន៍និងចំណេះដឹងថ្មីៗលើ ការដោះស្រាយបញ្ហានិងមានការកែលម្អកាន់តែប្រសើរឡើង | ២០០០ | - គណៈកម្មការសហគមន៍នេសាទ | ០១/០១-០៤-០៧-០១១/២០១៧ | ០១/០១-០៤-០៧-០១១/២០២១ | |
| | រៀបចំកំលាំងចុះបង្ក្រាបដល់ទីកន្លែងដោយសហការជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នជំនាញ | ២៣ដង/ខែ ឧបករណ៍នេសាទខុសច្បាប់ថយចុះបណ្តើៗ និងឈានទៅលុបបំបាត់ទាំងស្រុង | ១២០០០ | - អង្គការដៃគូ<br>- រដ្ឋបាលជលផល<br>- គណៈកម្មការសហគមន៍នេសាទ<br>- អាជ្ញាធរមូលដ្ឋាន | ០១/០១/២០១៧ | ៣០/០៣/២០២១ | រៀងរាល់ខែ |
| ៣-ការប្រើប្រាស់ឧបករណ៍នេសាទ | ២ដង/ឆ្នាំ ប្រជុំផ្សព្វផ្សាយអំពីផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍នេសាទគោកធ្លក | - សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍គោកធ្លក<br>- ឧបករណ៍នេសាទល្មើសច្បាប់ថយចុះជាបណ្តើរៗ<br>- ផលត្រីនៅក្នុងសហគមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានពេញមួយឆ្នាំ | ២៥០០ | - អង្គការដៃគូ<br>- រដ្ឋបាលជលផល<br>- គណៈកម្មការសហគមន៍នេសាទ<br>- អាជ្ញាធរមូលដ្ឋាន | ០១/០១-០៣-/២០១៧ | ០១/០១-០៣-/២០២១ | |
| | បិទផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍ ២ដង/ឆ្នាំ | | ១០០០ | | ០១/០២-០៦-/២០១៧ | ០១/០២-០៦-/២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ចែកចាយឯកសារផែនការសហគមន៍តាមផ្ទះ២ដង/ឆ្នាំ | | ១២៥០ | | ០១/០៣-០៧-/២០១៧ | ០១/០៣-០៧-/២០១៧ | |
| | ផ្សព្វផ្សាយតាមមេក្រូនូវផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍២ដង/ឆ្នាំ | | ១០០០ | | ០១/០១-០៨-/២០១៧ | ០១/០១-០៨-/២០១៧ | |
| ៤-ផ្សព្វផ្សាយច្បាប់ជលផល | -ផ្សព្វផ្សាយតាមការប្រជុំ<br>-ផ្សព្វផ្សាយតាមមេក្រូ<br>-ផ្សព្វផ្សាយតាមរយៈចែកឯកសារ | ៣ដង/ឆ្នាំ<br>ប្រជាពលរដ្ឋបានយល់ច្បាប់ជ.ផ ហើយឈប់ប្រព្រឹត្តការធ្វើនេសាទផ្ទុយនឹងច្បាប់ជលផល | ១៥០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-គណៈកម្មការសហគមន៍នេសាទ<br>-អាជ្ញាធរមូលដ្ឋាន | ០១/០៣-០៦-១០//២០១៧ | ០១/០៣-០៦-១០//២០១៧ | |
| ៥-ភាគទានពីសមាជិកសហគមន៍ពេលចូលជាសមាជិក | -ផ្សព្វផ្សាយជ្រើសរើសសមាជិក និងបង់ប្រាក់ភាគទាន<br>-ប្រមូលភាគទាន៥០០រៀល/ម្នាក់ | ២៩៧នាក់សុំចូលជាសមាជិក ៥០០រៀល/នាក់=១៤៨៥០០.រៀល | ៣៧ | សហគមន៍នេសាទ | ០១/០១/២០១៧ | ៣០/១២/២០២១ | |
| | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំ ១០០០រៀល/ម្នាក់ | ២៩៧នាក់ សុំចូលជាសមាជិក ១០០០រៀល/នាក់<br>បង់រាល់ឆ្នាំ រយៈពេល៥ឆ្នាំ ១៤៨៦០០០រៀល | ៣៧១ | សហគមន៍នេសាទ | ០១/០១/២០១៧ | ៣០/១២/២០២១ | |
| **សរុប** | | | **$= ៦៥០០៨** | 53758 | | | |

# តារាងកម្មវិធីការងារ

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៧ | | | | | | | | | | | | ២០១៨ | | | | | | | | | | | | ២០១៩ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **១-ការរៀបចំកន្លែងអភិរក្ស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានដឹងពីកន្លែងអភិរក្សនិងហាមឃាត់រាល់ការធ្វើនេសាទគ្រប់ប្រភេទ | | | x | | x | | | | | | | | | | x | | x | | | | | | | | | | x | | x | | | | | | | |
| ដាក់ស្លាកសញ្ញាតំបន់អភិរក្ស | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | |
| ដាំបង្គោលព្រំប្រទល់កន្លែងអភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | x | | | | | | | | | |
| ជម្រកសិប្បនិម្មិត (ដាក់ឬស្សីព័ទ្ធជុំវិញនិងដាក់កំប្លោកជាជម្រកត្រី | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | |
| **២-ការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នជំនាញ | x | | | | x | | | | x | | | | x | | | | x | | | | x | | | | x | | | | x | | | | x | | | |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំខែនិងត្រីមាស | x | | | x | | | x | | | | x | | x | | | x | | | x | | | | x | | x | | | x | | | x | | | | x | |
| រៀបចំកំលាំងចុះបង្ក្រាបដល់ទីកន្លែងដោយសហការជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នជំនាញ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| **៣-ការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទ | x | | x | | | | | | | | | | x | | x | | | | | | | | | | x | | x | | | | | | | | | |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| បិទផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទ | | x | | | | x | | | | | | | | x | | | | x | | | | | | | | x | | | | x | | | | | | |
| ចែកចាយឯកសារផែនការសហគមន៍តាមផ្ទះ | | | x | | | | x | | | | | | | | x | | | | x | | | | | | | | x | | | | x | | | | | |
| ផ្សព្វផ្សាយតាមមេក្រូនូវផែនការប្រើប្រាស់ឧបករណ៍នេសាទ | x | | | | | | | x | | | | | x | | | | | | | x | | | | | x | | | | | | | x | | | | |
| **៤.ផ្សព្វផ្សាយច្បាប់ជលផល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| -ផ្សព្វផ្សាយតាមការប្រជុំ<br>-ផ្សព្វផ្សាយតាមមីក្រូ<br>-ផ្សព្វផ្សាយតាមរយៈចែកឯកសារ | | | x | | | x | | | | x | | | | | x | | | x | | | | x | | | | | x | | | x | | | | x | | |
| **៥-ភាគទានពីសមាជិកសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រមូលភាគទានប្រចាំឆ្នាំ | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **១-ការរៀបចំកន្លែងអភិរក្ស** | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានដឹងពីកន្លែងអភិរក្សនិងហាមឃាត់រាល់ការធ្វើនេសាទគ្រប់ប្រភេទ | | | x | | x | | | | | | | | | x | | x | | | | | | | | |
| ដាក់ស្លាកសញ្ញាតំបន់អភិរក្ស | x | | | | | | | | | | | | x | | | | | | | | | | | |
| ដាំបង្គោលព្រំប្រទល់កន្លែងអភិរក្ស | | | x | | | | | | | | | | | | x | | | | | | | | | |
| ជម្រកសិប្បនិម្មិត (ដាក់ឬស្សីព័ទ្ធជុំវិញនិងដាក់កំប្លោកជាជម្រកត្រី | | x | | | | | | | | | | | | x | | | | | | | | | | |

| | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **២-ការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ** | | | | | | | | | | | | | | | | | | | | | | | | |
| ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នជំនាញ | x | | | | x | | | | x | | | | x | | | | x | | | | x | | | |
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍រៀបចំផែនការប្រចាំខែនិងត្រីមាស | x | | | x | | | x | | | | x | | x | | | x | | | x | | | | x | |
| រៀបចំកំលាំងចុះបង្ក្រាបដល់ទីកន្លែងដោយសហការជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នជំនាញ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| **៣-ការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទ | x | | x | | | | | | | | | | x | | x | | | | | | | | | |
| បិទផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទ | | x | | | | x | | | | | | | | x | | | | x | | | | | | |
| ចែកចាយឯកសារផែនការសហគមន៍តាមផ្ទះ | | | x | | | | x | | | | | | | | x | | | | x | | | | | |
| ផ្សព្វផ្សាយតាមមេក្រូនូវផែនការប្រើប្រាស់ឧបករណ៍នេសាទ | x | | | | | | | x | | | | | x | | | | | | | x | | | | |
| **៤.ផ្សព្វផ្សាយច្បាប់ជលផល** | | | | | | | | | | | | | | | | | | | | | | | | |
| -ផ្សព្វផ្សាយតាមការប្រជុំ<br>-ផ្សព្វផ្សាយតាមមីក្រូ<br>-ផ្សព្វផ្សាយតាមរយៈចែកឯកសារ | | | x | | | x | | | | x | | | | | x | | | x | | | | x | | |
| **៥-ភាគទានពីសមាជិកសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | |
| ប្រមូលភាគទានប្រចាំឆ្នាំ | x | | | | | | | | | | | | x | | | | | | | | | | | |

សូមគោរពជូន

មេឃុំគោកធ្លក

" ដើម្បីពិនិត្យនិងសម្រួល"

.........ថ្ងៃទី 16 ខែមករា ឆ្នាំ២០17

ប្រធានគណៈកម្មការសហគមន៍នេសាទគោកធ្លក

បានឃើញនិងបញ្ជូនមក

លោកនាយខណ្ឌរដ្ឋបាលជលផលតាកែវ

" ដើម្បីពិនិត្យនិងសម្រួល"

.........ថ្ងៃទី 18 ខែមករា ឆ្នាំ២០17

នាយផ្នែករដ្ឋបាលជលផលអង្គរបុរី

លេខ : 18/17

បានឃើញនិងបញ្ជូនមក

លោកនាយសង្កាត់រដ្ឋបាលជលផលគោកធ្លក

" ដើម្បីពិនិត្យនិងសម្រួល"

.........ថ្ងៃទី 16 ខែមករា ឆ្នាំ២០17

មេឃុំគោកធ្លក

បានឃើញនិងបញ្ជូនមក

លោកនាយអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ

" ដើម្បីពិនិត្យនិងសម្រួល"

.........ថ្ងៃទី ២០ ខែមករា ឆ្នាំ២០17

នាយខណ្ឌរដ្ឋបាលជលផលតាកែវ

បានឃើញនិងបញ្ជូនមក

លោកនាយផ្នែករដ្ឋបាលជលផលអង្គរបុរី

" ដើម្បីពិនិត្យនិងសម្រួល"

.........ថ្ងៃទី 17 ខែមករា ឆ្នាំ២០17

នាយសង្កាត់រដ្ឋបាលជលផលគោកធ្លក

លេខ : ០០៥ .........

បានឃើញនិងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យនិងសម្រេចដោយអនុគ្រោះ"

.........ថ្ងៃទី២៣ខែ មករា ឆ្នាំ២០១៧

នាយអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ

**សុខ ហុង**

លេខ : .........

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ .ថ្ងៃទី០៥ ខែ មីនា ឆ្នាំ២០១៧

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**